**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៣៣៤ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**គោរពជូន**

- **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
- **ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់**

**កម្មវត្ថុ :** ករណីសំណើសុំធ្វើការវិនិយោគបង្កើតផ្សារដោះដូរទំនិញ (ចេញ-ចូល) ឃ្លាំងស្តុក និងឡសំងួតផលិតផលកសិកម្ម ក្លឹបល្បែងផ្សងសំណាងគ្រប់ប្រភេទ (កាស៊ីណូ Casino) កន្លែងវាយកូនគោល ក្លឹបកីឡាគ្រប់ប្រភេទ ចំណតរថយន្ត និងស្ថានីយ៍ប្រេងឥន្ធនៈ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស អឹម ឌី អេស ថ្មដា អ៊ី ហ្សិត ខូអិលធីឌី (M.D.S THMORDA SEZ Co.,Ltd) ។

**យោង :**_លិខិតលេខ ០០៥/១០ អឌអថជ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់ក្រុមហ៊ុន អឹម ឌី អេស ថ្មដា អ៊ី ហ្សិត ខូអិលធីឌី (M.D.S THMORDA SEZ Co.,Ltd)

_ចំណាររបស់សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ចំពោះករណីសំណើរបស់ក្រុមហ៊ុន អឹម ឌី អេស ថ្មដា អ៊ី ហ្សិត ខូអិលធីឌី (M.D.S THMORDA SEZ Co.,Ltd) សុំធ្វើការវិនិយោគបង្កើតផ្សារដោះដូរទំនិញ (ចេញ-ចូល) ឃ្លាំងស្តុក និងឡសំងួតផលិតផលកសិកម្ម ក្លឹបល្បែងផ្សងសំណាងគ្រប់ប្រភេទ (កាស៊ីណូ Casino) កន្លែងវាយកូនគោល ក្លឹបកីឡាគ្រប់ប្រភេទ ចំណតរថយន្ត និងស្ថានីយ៍ប្រេងឥន្ធនៈ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស អឹម ឌី អេស ថ្មដា អ៊ី ហ្សិត ខូអិលធីឌី (M.D.S THMORDA SEZ Co.,Ltd) នៅលើផ្ទៃដីទំហំ ២.២៦៥ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិសាស្ត្រឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ នោះ រាជរដ្ឋាភិបាលបានសំរេចដូចខាងក្រោម ៖

១_យល់ព្រមតាមសំណើ

២_ចំពោះកាស៊ីណូហាមពលរដ្ឋខ្មែរចូលលេង

៣_ឯកឧត្តម សុខ ចិន្ដា បន្តជួយសម្រួលស្របតាមលិខិត ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០ ។

សេចក្ដីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ប៊ុន-អ៊ុយ**

**ចម្លងជូន**

*-ក្រសួងទេសចរណ៍*
*-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់*
*-ក្រសួងពាណិជ្ជកម្ម*
*-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*
*-ក្រសួងសាធារណការ និង ដឹកជញ្ជូន*
*-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ក្រុមហ៊ុន អឹម ឌី អេស ថ្មដា អ៊ី ហ្សិត ខូអិលធីឌី (M.D.S THMORDA SEZ Co.,Ltd)*
*_ឯកសារ-កាលប្បវត្តិ*

# ក្រុមហ៊ុន អឹម ឌី អេស ថ្មដា អេស អ៊ី ហ្សិត

## MDS THMORDA S.E.Z Co., Ltd

លេខ ០០៥/១០

ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១០

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំធ្វើការវិនិយោគបង្កើត ផ្សារដោះដូរទំនិញ (ចេញ-ចូល) ឃ្លាំងស្តុក និង ឡសំងួតផលិតផលកសិកម្ម ក្លិបល្បែងផ្សងសំណាងគ្រប់ប្រភេទ (កាស៊ីណូ Casino) កន្លែងវាយកូនគោល ក្លិបកីឡាគ្រប់ប្រភេទ ចំណតរថយន្ត និង ស្ថានីយ៍ប្រេងឥន្ធនៈ នៅក្នុងតំបន់សេដ្ឋកិច្ច **ពិសេស អិម ឌី អេស ថ្មដា អេស អ៊ី ហ្សិត ខូ អិល ធី ឌី (M.D.S THMORDA SEZ Co., Ltd.)** ។

**យោង:** លិខិតលេខ២០៣០/១០ ត.ស.ព ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ របស់ ក.អ.ក/ត.ស.ព ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជំរាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ***សូមមេត្តាជ្រាបថា*** : បន្ទាប់ពីទទួលបាននូវគោលការណ៍អនុញ្ញាតអោយក្រុមហ៊ុន **អិម ឌី អេស ថ្មដា អេស អ៊ី ហ្សិត** ធ្វើការវិនិយោគបង្កើតតំបន់ **សេដ្ឋកិច្ចពិសេស អិម ឌី អេស ថ្មដា** នៅលើផ្ទៃដីទំហំ ២.២៦៥ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិសាស្ត្រឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាមក ក្រុមហ៊ុនរបស់ខ្ញុំបាទបានខិតខំយ៉ាងខ្លាំងក្នុងការបំពេញភារកិច្ចតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានកំណត់ស្តីពីការរៀបចំដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននានានៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ និង ការពិភាក្សាជាមួយក្រសួងបរិស្ថានដើម្បីចុះកិច្ចសន្យាជួលទីតាំង ព្រមទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះធ្វើការវាស់វែង និង កំណត់និយាមកា ព្រំប្រទល់តំបន់អភិវឌ្ឍន៍ផងដែរ ។

ទន្ទឹមនឹងនេះដែរ ដើម្បីអាចចាប់ផ្តើមដំណើរការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស **អិម ឌី អេស ថ្មដា អេស អ៊ី ហ្សិត** អោយបានឆាប់តាមផែនការដែលបានគ្រោងទុក និង ដោយយោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នោះ ខ្ញុំបាទសូមគោរពស្នើសុំ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតអោយក្រុមហ៊ុនខ្ញុំបាទបានធ្វើការវិនិយោគលើគំរោងមួយចំនួននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស **អិម ឌី អេស ថ្មដា អេស អ៊ី ហ្សិត** ដូចបានស្នើសុំក្នុងកម្មវត្ថុខាងលើ ក្នុងគោលបំណងធ្វើអោយមានការទាក់ទាញកាន់តែខ្លាំងពីសំណាក់វិនិយោគិនទាំងក្នុង និង ក្រៅប្រទេស តាមរយៈការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច របស់តំបន់សេដ្ឋកិច្ចពិសេសនៅតំបន់ជាយដែននេះ ។ ក្រុម **អិម ឌី អេស ថ្មដា អេស អ៊ី ហ្សិត** របស់ខ្ញុំប្តេជ្ញាធ្វើការប្រែក្លាយតំបន់ដាច់ស្រយាលជាយដែននេះអោយក្លាយជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ធម្មជាតិ និង ការអភិវឌ្ឍន៍នានា ដើម្បីចូលរួមចំណែកក្នុងការលើកកំពស់សេដ្ឋកិច្ចរបស់ប្រទេសជាតិ ដោយមិនធ្វើអោយរាជរដ្ឋាភិបាលមានការ[illegible]ឡើយ ។

សេចក្តីដូចបានគោរពជំរាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ ។

**ប្រធានក្រុមហ៊ុន**

18-11-10

30-1-10